# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៤៩៥ ប្រក. កសក

# ប្រកាស
## ស្តីពី
## ការកំណត់ និងគ្រប់គ្រងប្រភេទត្រីលម្អ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ៥៧១ ប្រក.កសក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីវិធានការការពារប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍវារីវប្បកម្មត្រីលម្អគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់ប្រភេទត្រីលម្អគ្រប់ប្រភេទដែលអនុញ្ញាតឲ្យធ្វើវារីវប្បកម្ម អាជីវកម្ម ពាណិជ្ជកម្ម សន្និធិ និងសម្រាប់ការនាំចេញ នាំចូល និងឆ្លងកាត់។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើត្រីលម្អគ្រប់ប្រភេទដែលចិញ្ចឹមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលមានប្រភពពូជមកពី៖

- ធម្មជាតិ
- វារីវប្បកម្ម
- និងនាំចូល។

ប្រភេទត្រីលម្អ ដែលអនុញ្ញាតឲ្យចិញ្ចឹមមានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចធ្វើការកែសម្រួល ឬកំណត់បន្ថែមនូវប្រភេទត្រីលម្អតាមការចាំបាច់ដោយផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រជលផល។

ការគ្រប់គ្រងនិងការធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មត្រីលម្អគ្រប់ប្រភេទ ជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល។

**ប្រការ៥.-**

ការធ្វើវារីវប្បកម្មត្រីលម្អគ្រប់ប្រភេទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលថ្នាក់កណ្តាលចំពោះ ៖

-ត្រីលម្អគ្រប់ប្រភេទ ជាពូជក្នុងប្រទេសលើសពីមួយម៉ឺន (១០.០០០) ក្បាល

-ត្រីលម្អគ្រប់ប្រភេទ ជាពូជនាំចូលលើសពីប្រាំពាន់ (៥.០០០) ក្បាល

-ប្រភេទត្រីលម្អកម្រ និងជិតផុតពូជ ឬកំពុងរងគ្រោះថ្នាក់ចាប់ពីមួយ (១) ក្បាល ឡើងទៅ។

**ប្រការ៦.-**

ការបង្កើតទីតាំងទិញ លក់ សន្និធិ ការនាំចេញ នាំចូល ឬនាំឆ្លងកាត់នូវត្រីលម្អគ្រប់ប្រភេទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលថ្នាក់កណ្តាល។

ការដឹកជញ្ជូន ការនាំចូល និងការឆ្លងកាត់នូវប្រភេទត្រីលម្អគ្រប់ប្រភេទ ត្រូវមានវិញ្ញាបនបត្របញ្ជាក់គុណភាពពីប្រទេសនាំចេញ ។

វារីវប្បករមានកាតព្វកិច្ចការពារឲ្យបានដាច់ខាត មិនត្រូវឲ្យត្រីលម្អនោះរួច ឬលែងចូលក្នុងដែនទឹកធម្មជាតិឡើយ ជាពិសេសពូជនាំចូល ឬពូជបង្កាត់ថ្មី។

**ប្រការ៧.-**

ជនណាប្រព្រឹត្តផ្ទុយនឹងប្រការ៥ និងប្រការ៦ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍តាមមាត្រា៩៣ នៃច្បាប់ស្តីពីជលផល។

**ប្រការ៨.-**

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម និងប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ១៧ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល** :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងយុត្តិធម៌
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត រាជធានី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៩
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

ភ្ជាប់ប្រកាសលេខ២៥៥...ប្រក.កសក ចុះថ្ងៃទី....០៣....... ខែ....០៣.....ឆ្នាំ២០១៤

" ស្តីពីការកំណត់ប្រភេទត្រីលម្អ (ផ្នែកសមុទ្រ) "

| I. ត្រីលម្អទឹកសមុទ្រ(ក្នុង និងក្រៅស្រុក) | | | | | |
|---|---|---|---|---|---|
| លរ. | ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | រូបភាព | សំគាល់ |
| ១ | ត្រីត្លុក | *Amphiprion ocellaris* | Clown anemonefish |  | |
| ២ | ត្រីត្លុកក្រហម | *Premnas biaculeatus* | Spinecheek anemonefish |  | |
| ៣ | ត្រីខៀវពោះលឿង | *Pomacentrus coelestis* | Neon damselfish |  | |
| ៤ | ត្រីអុចសបី | *Dascyllus trimaculatus* | Threespot dascyllus |  | |
| ៥ | ត្រីចាបឆ្នូតខៀវ | *Paraglyphidodon oxyodon* | Bluestreak damselfish |  | |
| ៦ | ត្រីខៀវ | *Chrysiptera cyanea* | Sapphire devil |  | |
| ៧ | ត្រីខៀវកន្ទុយលឿង | *Chrysiptera parasema* | Yellow-tail blue damselfish |  | |
| ៨ | ត្រីត្លុកកាហ្វេ | *Amphiprion perideraion* | Pink skunk clown |  | |
| ៩ | ត្រីចាបក្រហម | *Hypsypops rubicundus* | Garibaldi damsel Garibaldi damselfish |  | |
| ១០ | ត្រីផ្កាខ្មៅ | *Acanthurus nigricauda* | Epaulette surgeonfish |  | |
| ១១ | ត្រីផ្កាឆ្នូតក្រហម | *Acanthurus sohal* | Sohal surgeonfish |  | |
| ១២ | ត្រីផ្កាព្រុយលឿង | *Acanthurus leucosternon* | Powder blue tang |  | |
| ១៣ | ត្រីសេះបង្កង់លឿង | *Zebrasoma flavescen* | Yellow tang |  | |

| | | | | | |
|---|---|---|---|---|---|
| ១៤ | ត្រីមេអំបៅលឿងខ្នង | *Hemitaurichthys polylepis* | Pyramid butterflyfish |  | |
| ១៥ | ត្រីមេអំបៅបង្កង់លឿង | *Chaetodon semilarvatus* | Bluecheek butterflyfish |  | |
| ១៦ | ត្រីមេអំបៅក្បាលខ្មៅ | *Heniochus intermedius* | Red sea bannerfish |  | |
| ១៧ | ត្រីមេអំបៅក្បាលស | *Heniochus acuminata* | White butterflyfish |  | |
| ១៨ | ត្រីមេអំបៅលឿង | *Forcipiger flavissimus* | butterfly fish longnose |  | |
| ១៩ | ត្រីរាជនីកន្ទុយលឿង | *Holacanthus ciliaris* | Queen angelfish |  | |
| ២០ | ត្រីរាជនីឆ្នូតខ្មៅ | *Pomacanthus sexstriatus* | Sixbar angelfish |  | |
| ២១ | ត្រីរាជនីក្បាលខៀវ | *Pomacanthus navarchus* | Bluegirdled angelfish |  | |
| ២២ | ត្រីរាជនីខ្នងលឿង | *Centropyge acanthops* | Orangeback angelfish |  | |
| ២៣ | ត្រីរាជនីគុកកែ | *Centropyge ferrugata* | Rusty angelfish |  | |
| ២៤ | ត្រីរាជនីសេះបង្កង់ | *Pygoplites diacanthus* | Regal angelfish |  | |
| ២៥ | ត្រីរាជជិនីបង្កង់លឿង | *Pomacanthus zonipectus* | Cortez angelfish |  | |
| ២៦ | ត្រីរាជនីលឿង | *Centropyge heraldi* | Yellow angelfish |  | |
| ២៧ | ត្រីរាជនីបារាំង | *Pomacanthus paru* | French angelfish |  | |
| ២៨ | ត្រីផ្កាថ្មបីពណ៌ | *Bodianus mesothorax* | Splitlevel hogfish |  | |
| ២៩ | ត្រីផ្កាថ្មក្រហម | *Coris gaimard* | African coris |  | |

| | | | | |
|---|---|---|---|---|
| ៣០ | ត្រីផ្កាថ្មកន្ទុយលឿង | *Bodianus rufus* | Spanish hogfish |  |
| ៣១ | ត្រីផ្កាថ្មច្រមុះខៀវ | *Gomphosus varius* | Bird wrasse |  |
| ៣២ | ត្រីរ៉ាដា | *Nemateleotris magnifica* | Firefish |  |
| ៣៣ | ត្រីកន្ទុយកន្ត្រៃ | *Ptereleotris evides* | Blackfin dartfish |  |
| ៣៤ | ត្រីឈីដៃ | *Pictichromis porphyrea* | Magenta dottyback |  |
| ៣៥ | ត្រីមុខកញ្ជ្រោង | *Siganus vulpinus* | Foxface |  |
| ៣៦ | ត្រីផ្លែល្ហុង | *Ostracion cubicus* | Yellow boxfish |  |
| ៣៧ | ត្រីក្រពតជប៉ុន | *Paraluterus prionurus* | False puffer |  |
| ៣៨ | ត្រីសិង្ហ | *Pterois volitans* | Red lionfish |  |
| ៣៩ | ត្រីអណ្ដាតឡាម | *Aeoliscus strigatus* | Razorfish |  |
| ៤០ | ត្រីកន្ទុយវែង | *Platax teira* | Longfin batfish |  |
| ៤១ | ត្រីពោងខ្មៅ | *Odonus niger* | Red-toothed triggerfish |  |
| ៤២ | ត្រីពោងកែវ | *Melichthys vidua* | Pinktail triggerfish |  |
| ៤៣ | ត្រីឆ្លាមឆ្នាខ្មៅ | *Chiloscyllium punctatum* | Brown-banded catshark |  |
| ៤៤ | ត្រីចាបកន្ទុយលឿង | *Monodactylus argenteus* | Silver moony |  |
| ៤៥ | ត្រីកញ្ចាញ់ចេកលឿង | *Synchiropus splendidus* | Mandarinfish |  |
| ៤៦ | ត្រីកញ្ចាញ់ចេកអុជលឿង | *Synchiropus picturatus* | Picturesque dragonet |  |

| | | | | | |
|---|---|---|---|---|---|
| ៤៧ | ត្រីម្ជូរីស | *Zanclus cornutus* | Moorish idol |  | |
| ៤៨ | ត្រីស្មាំងច្រមុះវែង | *Oxycirrhites typus* | Longnose hawkfish |  | |
| ៤៩ | សេះសមុទ្រគូជា | *Hippocampus kuda* | Spotted seahorse |  | |

# ឧបសម្ព័ន្ធ

ភ្ជាប់ប្រកាសលេខ ៤៨៤ ប្រក.កសក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០១៤
" ស្តីពីការកំណត់ប្រភេទត្រីលម្អ (ផ្នែកទឹកសាប) "

I. ត្រីលម្អទឹកសាបក្នុងស្រុក

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | រូបភាព | សំគាល់ |
|---|---|---|---|---|---|
| ១ | ត្រីនាគប្រាក់ | *Scleropages formosus* | Asian bonytongue |  | ជិតផុតពូជ |
| ២ | ត្រីនាគមាស | *Scleropages aureus* | Red tailed arowana |  | ជិតផុតពូជ |
| ៣ | ត្រីនាគក្រហម | *Scleropages legendrei* | Chili red arowana |  | ជិតផុតពូជ |
| ៤ | ត្រីកន្ធរប់ខ្លា | *Datnioides undecimradiatus* | Narrow barred tigerperch |  | កំពុងរងគ្រោះ |
| ៥ | ត្រីខ្លាឬត្រីបីកំណាត់ | *Puntius partipentazona* *Puntius tetrazona* | Tiger barb |  | ជិតផុតពូជ |
| ៦ | ត្រីកញ្ជាក់ស្លា | *Toxotes microlepis* | Small scale archerfish |  | |
| ៧ | ត្រីត្រសក់ក្រហម | *Probarbus jullieni* | Isok barb |  | ជិតផុតពូជ |
| ៨ | ត្រីត្រសក់ | *Probarbus labeamajor* | Thicklip barb |  | ជិតផុតពូជ |
| ៩ | ត្រីត្រសក់ស | *Probarbus labeaminor* | Thinlip barb |  | ជិតផុតពូជ |
| ១០ | ត្រីឆ្កិន | *Hypsibarbus pierrei* | Mekong silver barb |  | |

| | | | | | |
|---|---|---|---|---|---|
| ១១ | ត្រីឆ្ពិនមាស | *Hypsibarbus wetmorei* | Golden barb |  | |
| ១២ | ត្រីឆ្ពិនមូល | *Hypsibarbus malcolmi* | Goldfin tinfoil barb |  | |
| ១៣ | ត្រីឆ្ពិនប្រាក់ | *Barbonymus gonionotus* | Java/Silver barb |  | |
| ១៤ | ត្រីរមាស | *Osphronemus goramy* | Giant gourami |  | កំពុងរងគ្រោះ |
| ១៥ | ត្រីត្រចៀកដំរី | *Osphronemus exodon* | Elephant ear gourami |  | កំពុងរងគ្រោះ |
| ១៦ | ត្រីកន្ធរ | *Trichopodus pectoralis* | Snakeskin gourami |  | |
| ១៧ | ត្រីក្រាយ | *Chitala ornata* | Clown featherback |  | |
| ១៨ | ត្រីកំភ្លាញស្រែ | *Trichopodus trichopterus* | Three spot gourami |  | |
| ១៩ | ត្រីកំភ្លាញភ្លុក | *Trichogaster microlepis* | Moonlight gourami |  | |
| ២០ | ត្រីកញ្ជ្រូកភ្នំ | *Syncrossus beauforti* | Chameleon loach |  | |
| ២១ | ត្រីកញ្ជ្រូកស្ទឹង | *Yasuhikotakia morleti* | Skunk botia |  | |
| ២២ | ត្រីកញ្ជ្រូកខ្មៅ | *Yasuhikotakia eos* | Sun loach |  | |

| | | | | | |
|---|---|---|---|---|---|
| ២៣ | ត្រីកញ្ជ្រូកឆ្នូត | *Syncrossus helodes* | Tiger botia |  | |
| ២៤ | ត្រីកញ្ជ្រូកលឿង | *Yasuhikotakia lecontei* | Yellow loach |  | |
| ២៥ | ត្រីកញ្ជ្រូកក្រហម | *Yasuhikotakia modesta* | Orange fin loach |  | |
| ២៦ | ត្រីកញ្ជ្រូកតឿ | *Yasuhikotakia sidthimunki* | Dwarf botia |  | |
| ២៧ | ត្រីកាហែលឿង | *Barbonymus schwanenfeldii* | Tinfoil barb |  | |
| ២៨ | ត្រីកាហែក្រហម | *Barbonymus altus* | Red tailed tinfoil |  | |
| ២៩ | ត្រីក្រឹមមាស | *Betta splendens* | Siamese fighting fish |  | |
| ៣០ | ត្រីក្រឹមក្តារ | *Trichopsis vittata* | Croaking gourami |  | |
| ៣១ | ត្រីក្រឹមទន្សាយ | *Trichopsis pumila* | Talking gourami |  | |
| ៣២ | ត្រីក្រឹមព្រៃ | *Betta prima* | |  | |
| ៣៣ | ត្រីចង្វាស្រលូង | *Rasbora borapetensis* | Blackline rasbora |  | |
| ៣៤ | ត្រីចង្វាឆ្នូត | *Rasbora espei* | Lambchop rasbora |  | |
| ៣៥ | ត្រីចង្វាអង្គរ | *Garra cambodgiensis* | Stonelapping minow |  | |
| ៣៦ | ត្រីចង្វារនោងវែង | *Garra fasciacauda* | |  | |
| ៣៧ | ត្រីចង្វារនោង | *Labocheilos delacouri* | Lesser double-lipped carp |  | |
| ៣៨ | ត្រីដងដាវ | *Luciosoma setigerum* | Shark minnow |  | |

| | | | | | |
|---|---|---|---|---|---|
| ៥៦ | ត្រីខ្សាន | *Glossogobius sparsipapillus* | Linecheek tank goby |  | |
| ៥៧ | ត្រីខ្សានអុច | *Rhinogobius mekongianus* | |  | |
| ៥៨ | ត្រីផ្លោង | *Zenarchopterus ectuntio* | Halfbeak |  | |
| ៥៩ | ត្រីស្លាត | *Notopterus notopterus* | Bronze featherback |  | |
| ៦០ | ត្រីស្លឹកបាស | *Scatophagus argus* | Spotted scat |  | |

II.ត្រីលម្អទឹកសាបក្រៅស្រុក

| ល.រ. | ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | រូបភាព | សំគាល់ |
|---|---|---|---|---|---|
| ១ | ត្រីឡូហាន | *Vieja synspila* | Redhead cichlid |  | |
| ២ | ត្រីក្រពើ | *Cymbacephalus beauforti* | Crocodile fish |  | |
| ៣ | ត្រីក្រាញ់មាស | *Astronotus ocellatus* | Oscar, Tiger oscar, Marble cichlid |  | |
| ៤ | ត្រីហុងកុង | *Poecilia latinna may be P. latipinna (Sailfin Molly) or hybrids and cultivated varieties of different Poecilia species.* | Sailfin molly |  | |
| ៥ | ត្រីនាងចម | *Cyprinus carpio* | Common carp |  | |
| ៦ | ត្រីកន្ទុយបី | *Carassius auratus auratus* | Goldfish |  | |
| ៧ | ត្រីប្រាំពីរពណ៌ | *Poecilia reticulate* | Guppy |  | |
| ៨ | ត្រីសេក | *Scarus frenatus* | Blood parrot cichid |  | |

| | | | | | |
|---|---|---|---|---|---|
| ៩ | ត្រីពណ៌ | *Paracheirodon innesi* | Neon tetra |  | |
| ១០ | ត្រីត្រចៀកកាំ | *Pterophyllum scalare* | Angelfish |  | |
| ១១ | ត្រីកន្ទ្រប់អាមេរិកាំង | *Symphysodon aequifasciatus* | Discus fish |  | |
| ១២ | ត្រីត្រចៀកភឿក | *Pterophyllum sp.* | Albino angel |  | |
| ១៣ | ត្រីត្រចៀកព្រុយវែង | *Pterophyllum altum* | Altum angel-true wild strain |  | |
| ១៤ | ត្រីក្រឹមទន្សាយឆ្នូតខ្មៅ | *Apistogramma sp.* | Assorted apistogramma |  | |
| ១៥ | ត្រីត្រចៀកខ្មៅ | *Pterophyllum sp.* | Black angel |  | |
| ១៦ | ត្រីកន្ទ្រប់ពេជ្រខៀវ | *Symphysodon sp.* | Blue diamond discus |  | |

| | | | | | |
|---|---|---|---|---|---|
| ១៧ | ត្រីកំភ្លាញខៀវ | *Trichogaster trichopterus* | Blue gourami |  | |
| ១៨ | ត្រីកំភ្លាញមាស | *Trichogaster trichopterus* | Gold gourami |  | |
| ១៩ | ត្រីខ្លាបង្កង់ | *Puntius pentazona* | Hexazon barb |  | |
| ២០ | ត្រីត្រចៀកកាំលៀង | *Pterophyllum sp.* | Koi angel |  | |
| ២១ | ត្រីកន្ទ្រប់សមុទ្រ | *Symphysodon sp.* | Ocean green discus |  | |
| ២២ | ត្រីក្រឹមប៉ាវ៉ា | *Trichogaster trichopterus* | Opaline gourami |  | |
| ២៣ | ត្រីក្រឹមគុជ | *Trichogaster leeri* | Pearl gourami |  | |
| ២៤ | ត្រីកន្ទ្រប់ព្រាបលឿង | *Symphysodon spp.* | Pigeon blood discus |  | |
| ២៥ | ត្រីកន្ទ្រប់ក្រហម | *Symphysodon sp.* | Red marlboro discus |  | |
| ២៦ | ត្រីកន្ទ្រប់ខៀវ | *Symphysodon spp.* | Red turquoise discus |  | |

| | | | | | |
|---|---|---|---|---|---|
| ២៧ | ត្រីកន្ត្រប់ស្តេចក្រហម | *Symphysodon sp.* | Royal red discus |  | |
| ២៨ | ត្រីអប្សរប្រាក់ | *Pterophyllum sp.* | Silver zebra angel |  | |
| ២៩ | ត្រីក្រចៀកកាំខ្លា | *Pterophyllum sp.* | Smokey leopard veil angel |  | |
| ៣០ | ត្រីថាសស្បែកពស់ | *Symphysodon spp.* | Snakeskin discus |  | |
| ៣១ | ត្រីក្រឹមភៀក | *Hemigrammus caudovittatus* | Albino buenos aires tetra |  | |
| ៣២ | ត្រីក្រឹមភៀកលឿង | *Puntius titteya* | Albino cherry barb |  | |
| ៣៣ | ត្រី | *Apteronotus albifrons* | Black ghost knifefish |  | |
| ៣៤ | ត្រីក្រឹមអំពូល | *Hyphessobrycon herbertaxelrodi* | Black neon tetra |  | |
| ៣៥ | ត្រីក្រឹមកញ្ជាញ់ប្រាស់ឆ្នូត | *Gymnocorymbus ap.* | Black skirt tetra |  | |
| ៣៦ | ត្រីក្រឹមបេះដូងឆ្នូតក្រហម | *Hyphessobrycon erythrostigma* | Bleeding heart tetra |  | |

| | | | | | |
|---|---|---|---|---|---|
| ៣៧ | ត្រីក្រឹមអុចខ្មៅកន្ទុយ | *Hemigrammus caudovittatus* | Buenos aires tetra |  | |
| ៣៨ | ត្រីក្រឹមបង្កង់ទ្រូងលឿង | *Pseudotropheus crabro* | Bumblebee cichlid |  | |
| ៣៩ | ត្រីប្រាក់ព្រុយលឿង | *Neolamprologus caudopunctatus* | Caudopunctatus cichlid |  | |
| ៤០ | ត្រីថាសបង្កង់ខ្លួនខៀវ | *Symphysodon spp.* | Checkerboard discus |  | |
| ៤១ | ត្រីក្រឹមត្បូងខៀវ | *Metriaclima callainos* | Cobalt blue zebra cichlid |  | |
| ៤២ | ត្រីក្រឹមសេះបង្កង់ | *Pseudotropheus demasoni* | Demasoni cichlid |  | |
| ៤៣ | ត្រីក្រឹមភ្លើង | *Apistogramma agassizi* | Double full red agassizi cichlid |  | |
| ៤៤ | ត្រីលឿងរាជ | *Labidochromis caeruleus* | Electric yellow cichlid |  | |
| ៤៥ | ត្រីឡាហានខ្លា | *Cyphotilapia frontosa* | Frontosa cichlid |  | |
| ៤៦ | ត្រីមាសឆ្នូតខ្មៅ | *Puntius sachsii* | Gold barb |  | |

| | | | | | |
|---|---|---|---|---|---|
| ៤៧ | ត្រីត្រចៀកកាំមាស | *Pterophyllum sp.* | Gold veil angel |  | |
| ៤៨ | ត្រីកន្ត្រប់ខៀវ | *Symphysodon aequifasciata* | Green discus |  | |
| ៤៩ | | *Puntius tetrazona* | Green tiger barb |  | |
| ៥០ | ត្រីកំប្លុក | *Rasbora heteromorpha* | Harlequin rasbora |  | |
| ៥១ | ត្រីប្រាក់អុជ | *Nandopsis octofasciatum* | Jack dempsey |  | |
| ៥២ | | *Apistogramma cacatuoides* | Orange cockatoo cichlid |  | |
| ៥៣ | | *Puntius fasciatus* | Panda barb |  | |
| ៥៤ | | *Apistogramma njessini* | Panda dwarf cichlid |  | |
| ៥៥ | | *Pimelodus pictus* | Pictus cat |  | |
| ៥៦ | | *Dianema longibarbis* | Porthole catfish |  | |

| | | | | | |
|---|---|---|---|---|---|
| ៥៧ | | *Laetacara Curviceps* | Red breast smiling cichlid |  | |
| ៥៨ | | *Moenkhausia sanctaefilomene* | Red eye tetra |  | |
| ៥៩ | | *Glossolepis incisis* | Red irian rainbow |  | |
| ៦០ | ត្រីកន្រ្ទប់អុចក្រហម | *Symphysodon sp.* | Red spot green discus |  | |
| ៦១ | | *Phractocephalus hemioliopterus* | Redtail cat |  | |
| ៦២ | | *Osteoglossum bicirrhosum* | Silver arowana |  | |
| ៦៣ | | *Puntius rhombocellatus* | Snakeskin barb |  | |
| ៦៤ | | *Iriatherina werneri* | Threadfin rainbow |  | |
| ៦៥ | | *Lamprologus tretacephaleus* | Tretocephalus cichlid |  | |

| | | | | | |
|---|---|---|---|---|---|
| ៦៦ | | *Hemigrammus bleheri* | True rummynose tetra |  | |
| ៦៧ | | *Copadichromis borleyi* | Yellowfin borleyi cichlid |  | |
| ៦៨ | | *Puntius conchonius* | Rosy barb, male |  | |
| ៦៩ | | *Brachydanio Kerri* | Turquoise danio |  | |
| ៧០ | ត្រីកន្ទ្រប់លឿង | *Symphysodon sp.* | Yellow marlboro discus |  | |